# ចូរបែរទៅរកព្រះអម្ចាស់

*អែលឌើរ ដូណាល អិល ហាលស្ត្រម*
*គណៈប្រធាននៃពួកចិតសិប*

ជាច្រើនឆ្នាំកន្លងទៅហើយ ខ្ញុំបានសង្កេតឃើញការខូចចិត្តមួយ... ដែលបានប្រែក្លាយទៅជាសោកនាដកម្ម។ គូស្វាមីភរិយាវ័យក្មេងមួយគូជិតនឹងសម្រាលកូនទីមួយរបស់ពួកគេទៅហើយ។ ជីវិតរបស់ពួកគេពោរពេញ ទៅដោយក្តីរំពឹងទុក និងក្តីរំភើបចំពោះបទពិសោធន៍ដ៏ធំនេះ។ អំឡុងពេលសំរាលទារក ភាពស្មុគ្រស្មាញមួយ បានកើតឡើង ហើយទារកត្រូវស្លាប់។ ការខូចចិត្តនោះបានប្រែក្លាយជាទុក្ខសោក ទុក្ខសោកនោះបានប្រែក្លាយទៅជា កំហឹង កំហឹងប្រែក្លាយទៅជាការស្តីបន្ទោស ការស្តីបន្ទោសប្រែ ក្លាយទៅ ជាការសងសឹកចំពោះវេជ្ជបណ្ឌិត ដែលទទួលខុសត្រូវចំពោះការសំរាលនោះទាំងស្រុង។ ឪពុកម្តាយ និងសមាជិកគ្រួសារ ផ្សេងទៀតបានចូលរួមចំណែក យ៉ាងខ្លាំង ពួកគេស្វែងរកធ្វើការ បំផ្លាញ កេរ្តិ៍ឈ្មោះ និងអាជីពរបស់គ្រូពេទ្យនោះ។ ជាច្រើនសប្តាហ៍ ជាច្រើនខែកន្លង ភាពល្វីងជូចត់នោះ បានស៊ីបំផ្លាញក្រុមគ្រួសារ ភាពល្វីងជូរចត់របស់ពួកគេបាន រាលដាលដល់ព្រះអម្ចាស់។ «តើទ្រង់ អនុញ្ញាតឱ្យហេតុការណ៍ដ៏អាក្រក់នេះកើត ឡើងដោយរបៀបណា?» ពួកគេបានបដិសេធ កិច្ចខិតខំម្តងហើយម្តងទៀត របស់អ្នកដឹកនាំ និងសមាជិកសាសនាចក្រ ចំពោះការលួង លោមខាង វិញ្ញាណ និងខាងសតិអារម្មណ៍ ហើយក្នុងគ្រានោះបានផ្តាច់ទំនាក់ទំនងជាមួយសាសនាចក្រ។ មកដល់ ពេលនេះក្រុមគ្រួសារបួនជំនាន់ហើយ ដែលបានរងឥទ្ធិពលដោយសាររឿងនេះ។ ដែលគ្រាមុនធ្លាប់មាន សេចក្តីជំនឿ និងការលះបង់ចំពោះព្រះអម្ចាស់ និងសាសនាចក្រ ហើយគ្មានសកម្មភាពខាង វិញ្ញាណ ដោយសមាជិក គ្រួសាររាប់ទសវត្សរ៍មកហើយ។

នៅក្នុងគ្រាដ៏ពិបាកបំផុតក្នុងជីវិត ជារឿយៗគឺមានប្រភពនៃភាពសុខសាន្តតែមួយគត់។ ម្ចាស់នៃមេត្រីភាពគឺព្រះយេស៊ូវ គ្រីស្ទ ទ្រង់បានពង្រីកព្រះគុណរបស់ទ្រង់ដោយក្តីអញ្ជើញ «អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឱ្យអ្នករាល់គ្នាឈប់សំរាក។ ចូរទទួលនឹមខ្ញុំ ហើយរៀននឹង ខ្ញុំចុះ...នោះអ្នករាល់គ្នា នឹងបានសេចក្តីសំរាក ដល់ព្រលឹង»។ (ម៉ាថាយ 11:28--29 )។ ទ្រង់បានសន្យាបន្ថែមទៀតថា «...ខ្ញុំទុកសេចក្តីសុខសាន្តនៅនឹងអ្នក រាល់គ្នាៈ ហើយដែលខ្ញុំឱ្យនោះមិនមែនដូចជាលោកីយឱ្យទេ» (យ៉ូហាន 14:27 )។

ជីដូនជីតាខាងឪពុករបស់ខ្ញុំមានកូនពីរ កូនប្រុសម្នាក់ (ឪពុករបស់ខ្ញុំ) និងកូនស្រីម្នាក់។ បន្ទាប់ពីបំរើបេសកកម្ម និងកងទ័ពនៅហាវៃមក ឪពុករបស់ខ្ញុំបានត្រឡប់ទៅកាន់កោះវិញនៅក្នុងឆ្នាំ 1946 ដើម្បីស្ថាបនាវិជ្ជាជីវៈ ផ្ទាល់ខ្លួនរបស់គាត់ និងចិញ្ចឹមក្រុមគ្រួសាររបស់គាត់ផ្ទាល់។ ឪពុកម្តាយរបស់គាត់រស់នៅក្នុងទីក្រុង សតល៍ លេក ក៏ដូចជាប្អូនស្រីរបស់គាត់ដែរ។ គាត់បានរៀបការនៅក្នុងឆ្នាំ 1946 ហើយបួនឆ្នាំក្រោយមកមានទម្ងន់ បានកូនប្រុសម្នាក់។ គឺមានអ្វីមួយពិសេសណាស់ដែលឪពុកម្តាយរំពឹងថា នឹងមាន

កូនស្រី (ដែលនៅក្នុងពេលនោះ មានកូនស្រីតែម្នាក់គត់) ផ្តល់កំណើតជាលើកដំបូង។ គ្មាននរណាម្នាក់ដឹងថាគាត់មានកូនភ្លោះនោះទេ។ ជាអកុសល នាង និងកូនភ្លោះទាំងពីរបានស្លាប់អំឡុងពេលឆ្លងទន្លេ។

ជីដូនជីតារបស់ខ្ញុំបានខូចចិត្ត។ ទោះជាយ៉ាងណាក្តី ទុក្ខព្រួយរបស់ពួកគេ ភ្លាមៗនោះបានបែរទៅរកព្រះអម្ចាស់ និងដង្វាយធួនរបស់ទ្រង់។ ដោយពុំចាំបាច់រស់នៅក្នុងទុក្ខព្រួយ ហើយហេតុអ្វីបានជារឿង នេះកើតឡើង និងត្រូវស្តីបន្ទោសនរណានោះ ពួកគាត់បានស្វែងរក «សេចក្តី សុខសាន្ត...ដែលហួស ពីអស់ទាំងគំនិត» (ភីលីព 4:7 ) ហើយបានផ្តោតយកចិត្តទុកដាក់ ក្នុងការរស់នៅក្នុងជីវិតសុចរិត។ លោកតាលោកយាយរបស់ខ្ញុំមិនមែន ជាអ្នកមានទ្រព្យសម្បត្តិទេ ពួកគេមិនដែលមានតួនាទីសំខាន់នៅក្នុងសង្គម ពួកគេមិនដែលកាន់តួនាទីខ្ពស់នៅក្នុងសាសនាចក្រ--- ពួកគេគ្រាន់តែជាពួកបរិសុទ្ធ ថ្ងៃចុងក្រោយដែលមានការលះបង់សាមញ្ញប៉ុណ្ណោះ។

បន្ទាប់ពីចូលនិវត្តន៍នៅក្នុង 1956 ពួកគាត់បានផ្លាស់ទៅរស់នៅហាវ៉ៃ ជាមួយសាច់ញាតិ តែមួយគត់ របស់ពួកគាត់។ ប៉ុន្មានឆ្នាំក្រោយមកក្រុមគ្រួសាររបស់ពួកគាត់ នៅតែរស់នៅដោយក្តីស្រឡាញ់ បំរើនៅក្នុងសាសនាចក្រ (ពួក គាត់បានឱ្យតម្លៃជាពិសេសជាង 20 ឆ្នាំដែលជាអ្នកធ្វើពិធីការនៅក្នុងព្រះវិហារបរិសុទ្ធ) ហើយអ្វីដែលសំខាន់បំផុតនោះ គឺពួកគាត់រីករាយក្នុងការនៅជាមួយគ្នា។ ពួកគាត់មិនចង់នៅឃ្លាតឆ្ងាយពីគ្នាទេ ហើយពួកគាត់ ក៏បាននិយាយផងដែរថា នរណាដែលស្លាប់មុន ត្រូវរកមធ្យោបាយយ៉ាងណាឱ្យពួកគាត់ជួបជុំគ្នាឱ្យបានឆាប់។ នៅថ្ងៃខួបកំណើតទី  90 របស់ពួកគាត់ជិតមកដល់ និងបន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍អស់រយៈពេល  65 ឆ្នាំ មក ពួកគាត់បានទទួលមរណៈភាព មួយម៉ោងឃ្លាតពីគ្នាប៉ុណ្ណោះ ដោយជម្ងឺចាស់ជរា។ ក្នុងនាមជាប៊ីស្សពរបស់ពួកគាត់ ខ្ញុំបានដឹកនាំពិធីបុណ្យសពទាំងពីររបស់ពួកគាត់។

សេចក្តីស្មោះត្រង់របស់លោកតា អាត និងលោកយាយ លូ មានជាពិសេសនៅពេលដែល ពួកគាត់ប្រឈមមុខជាមួយនឹងការពិបាក ឥឡូវនេះមានឥទ្ធិពលដល់កូនចៅជំនាន់ក្រោយបួនជំនាន់។ ដោយផ្ទាល់ និងយ៉ាងជ្រាលជ្រៅ វាមានឥទ្ធិពលចំពោះកូនរបស់ពួកគាត់ (ឪពុករបស់ខ្ញុំ) និងម្តាយរបស់ខ្ញុំ នៅពេលកូនស្រីបង្កើតរបស់ឪពុកម្តាយខ្ញុំ ជាកូនពៅរបស់ពួកគាត់ បានស្លាប់ដោយសារ មានបញ្ហាក្នុងពេលសំរាលទារក។ ដប់ថ្ងៃក្រោយពីសំរាលទារកហើយ គាត់បានទទួលមរណភាពក្នុងអាយុ 34 ឆ្នាំ បន្សល់ទុកកូនបួននាក់ ដែលកូនទាំងនោះចន្លោះអាយុពីដប់ថ្ងៃ ទៅប្រាំបីឆ្នាំ។ ដោយពួកគាត់ធ្លាប់បានមើលឃើញគំរូកាលពីជំនាន់មុន ឪពុកម្តាយរបស់ខ្ញុំ--- គ្មានការស្ទាក់ស្ទើរអ្វីទាំងអស់--- បានបែរទៅរកព្រះអម្ចាស់ចំពោះរឿងអាក្រក់នេះ។

នៅទូទាំងពិភពលោក និងនៅក្នុងចំណោមសមាជិកភាពនៃសាសនាចក្រ មាននូវក្តីអំណរដ៏អស្ចារ្យ និងការឈឺ ចាប់ដ៏ខ្លាំងបំផុត។ ទាំងពីរចំណុចនេះគឺជាផ្នែកមួយនៃផែនការ។ បើគ្មានមួយ យើងមិនអាចយល់មួយទៀតឡើយ។ «ហើយមានមនុស្សលោក ដើម្បីគេអាចមានសេចក្តីអំណរ» (នីហ្វៃទី 2  2:25)

ហើយ «ត្បិតជាការចាំបាច់ត្រូវតែ មានការផ្ទុយចំពោះរឿងសព្វសារពើរ» (នីហ្វៃទី 2  2:11 ) ដែលមិនមែនជាការផ្ទុយគ្នា នោះទេ ទាំងពីរនេះគឺ បំពេញឱ្យគ្នាទៅវិញទៅមក។ ដើម្បីពិពណ៌នា អំពីអារម្មណ៍របស់គាត់ នៅពេលគាត់បែរទៅរក ព្រះអម្ចាស់ អាលម៉ាតូច បាននិយាយថា៖ «ព្រលឹងឪពុកបានពោរពេញទៅដោយ សេចក្តីអំណរ លើសជាងការឈឺចាប់ របស់ឪពុកទៅទៀត» (អាលម៉ា 36:20 )។

មនុស្សខ្លះបានយកឈ្នះលើបញ្ហារធំៗ អ្នកខ្លះទៀតធ្វើឱ្យបញ្ហារតូចទៅជាធំ។ ស៊ីម៉ូន រ៉ាយឌឺស៍ ជាអ្នកដឹកនាំសាសនាខេមប៉េលលីតេម្នាក់ ក្រោយមកបានឮអំពីសាសនាចក្រ ហើយបានជួបជាមួយលោក យ៉ូសែប ស្ម៊ីធ ។ ដោយបានទទួលបទពិសោធន៍ខាងវិញ្ញាណ លោកបានចូលរួមក្នុងសាសនាចក្រនៅខែ មិថុនា ឆ្នាំ 1831។ ក្រោយមកមិនយូរប៉ុន្មាន គាត់ត្រូវបានតែងតាំងជាអែលឌើរ និងបានហៅឱ្យបំរើបេសកកម្ម។ ប៉ុន្តែនៅក្នុងសំបុត្រ ហៅបំរើរបស់គាត់មកពីគណៈប្រធានទីមួយ និងសំបុត្រជាផ្លូវការពីគណៈកម្មការ ហៅឱ្យផ្សព្វផ្សាយនោះ បានសរសេរឈ្មោះរបស់គាត់ខុស...ដោយខុសអក្សរមួយតួរ។ ត្រកូលរបស់គាត់ប្រកប R-i-d-e-r មិនត្រឹមត្រូវ អ្វីដែលត្រូវគឺ R-y-d-e-r។ ចំណុចនេះធ្វើឱ្យ គាត់មានចម្ងល់អំពីការហៅរបស់គាត់ ហើយតើបែបបទទាំងនោះ ចេញមកពីណា។ គាត់ជ្រើសរើសមិនទៅបេសកកម្ម ហើយបានធ្លាក់ចុះ ដែលក្រោយមកដឹកនាំទៅរកការស្អប់ខ្ពើម និងមានចេតនាប្រឆាំង ជាមួយ យ៉ូសែប និងសាសនាចក្រ។ នៅខែ មិនា ឆ្នាំ 1832 នៅពេល យ៉ូសែប ស្ម៊ីធ និងស៊ិដនី រិកដុន  ត្រូវបានគេបង្ខិតបង្ខំឱ្យចេញពីផ្ទះ ចន ចនសិន នាពេលយប់ដោយពួកមនុស្សកំណាច បានចាក់ជ័រកៅស៊ូរលើលោក និងដាក់រោមសត្វលើលោក មានសម្លេងមួយបានស្រែកយ៉ាងខ្លាំងថា «សៃម៉ូន សៃម៉ូន តើធុងជ័រកៅស៊ូនៅឯណា?» (Joseph Smith, History of the Church 1:262—263 )។ រយៈពេលតិចជាងដប់ខែប៉ុណ្ណោះ សៃម៉ូ រ៉ាយឌ័រ ផ្លាស់ប្តូរពីអ្នកប្រែចិត្តដ៏ក្លាហាន ទៅជាមេពួកមនុស្ស កំណាច គាត់ចាប់ផ្តើមបដិសេធ ព្រះវិញ្ញាណ ដោយសារការអាក់អន់ចិត្តចំពោះរឿងសរសេរឈ្មោះគាត់ខុស... ដោយអក្សរមួយតួរ។ មិនថាបញ្ហារមានទំហំប៉ុនណ្ណានោះទេ របៀបដែលយើងឆ្លើយតបអាច តម្រង់ផ្លូវនៃជីវិតរបស់យើង។

ព្យាការី យ៉ូសែប ស្ម៊ីធ បានផ្តល់ជាគំរូមួយក្នុងការប្រឈរមុខនឹងសោកនាដកម្ម និងបច្ចាមិត្តផ្ទាល់ខ្លួន។ បានបើកសម្តែងដល់លោកអំឡុងពេលដែលលោកស្ថិតនៅក្នុងបរិយាកាសមួយដែលគ្មានធម៌មេត្តា នៅក្នុងគុក លិបឺធី  ដែលនេះគឺជាការដឹកនាំដ៏ទេវភាព (ដែលនោះជាការពិពណ៌នាអំពីជីវិតរបស់ យ៉ូសែប ដែលស្ថិតក្នុងដំណាក់កាលនោះ ហើយក៏ដើម្បីជាការដាស់តឿនផងដែរ)៖ ហើយ «ពួកល្ងង់ខ្លៅនឹង សើចចំអកអ្នក... បើសិនជាអ្នកត្រូវបានហៅ ឱ្យឆ្លង កាត់សេចក្តីវេទនា បើសិនជាអ្នកមានគ្រោះ នៅក្នុងចំណោមពួកបងប្អូនអ្នក... បើសិនជាអ្នកត្រូវគេចោទ ដោយការចោទ ក្លែងក្លាយគ្រប់បែបយ៉ាង បើសិនជាពួកខ្មាំងសត្រូវរបស់អ្នកសង្កត់មកលើអ្នក... ហើយបើសិនជាអ្នកត្រូវបោះទៅក្នុងរណ្តៅ ឬទៅក្នុងកណ្តាប់ ដៃនៃពួកឃាតករ...ហើយអស់ទាំងធនធាតុប្រមូលគ្នា រាំងផ្លូវ ហើយទោះបីលើសជាង អ្វីៗទាំងអស់ បើសិនជាចង្ការមាត់នៃស្ថាននរក និងហារត្របាក់អ្នកក្តី បុត្រយើងអើយ ចូរអ្នកដឹងថា គ្រប់ការណ៍ទាំងនេះនឹងផ្តល់ការពិសោធន៍ដល់អ្នក ហើយនឹងទៅជាការល្អដល់អ្នកទៅវិញ» (គ. និង ស.  122:1, 5--7 )។

បន្ទាប់មក មានសេចក្តីថ្លែងដ៏ជ្រាលជ្រៅថា៖ «កូនមនុស្សបានចុះទាបជាងការណ៍ទាំងនោះ ទៅទៀត។ តើអ្នកធំជាងទ្រង់ឬអី?» (គ. និង ស. 122:8 )។ បន្ទាប់ពីខនេះមកក៏មានសេចក្តីណែនាំ និងសេចក្តីសន្យាដ៏អស្ចារ្យយ៉ាងច្បាស់ថា។ «ហេតុដូច្នេះហើយ កូនកាន់ផ្លូវឱ្យខ្ជាប់ ហើយ បព្វជិតភាព នឹងនៅជាមួយអ្នក ត្បិតកំរិតទាំងឡាយរបស់ពួកគេត្រូវបានចាត់ទុក... ហេតុដូច្នេះហើយ ចូរកុំខ្លាចនូវអ្វី ដែលមនុស្សអាចប្រព្រឹត្តនោះឡើយ ត្បិតព្រះទ្រង់គង់នៅជាមួយអ្នក ជារៀងដរាបតទៅ» ( គ. និង ស. 122:9 )។

ប៉ុន្មានឆ្នាំក្រោយមកទៀត យ៉ូសែប ស៊្មីធ បានបន្តដល់ទីបញ្ចប់ដោយសេចក្តីសុចរិត នៅក្នុងជីវិតដែលពោរពេញ ទៅដោយការពិបាក។ លោកខិតខំផ្តល់ឱ្យនូវសក្ខានុពលដែលពោរពេញទៅដោយសេចក្តីជំនឿ «ហើយរីឯគ្រោះដែលខ្ញុំ ត្រូវបានហៅឱ្យឆ្លងកាត់ នោះហាក់ដូចជាតូចតាចចំពោះខ្ញុំ... ទឹកជ្រៅនេះហើយដែលខ្ញុំធ្លាប់ហែលកាត់...ខ្ញុំ... សរសើរ ដំកើងក្នុងសេចក្តីវេទនា ត្បិត... ព្រះ [បាន ] រំដោះខ្ញុំឱ្យរួច ពីការណ៍ទាំងអស់ ហើយនឹងរំដោះខ្ញុំឱ្យរួចពីអំណិះតទៅ» (គ. និង ស. 127:2 )។ យ៉ូសែប មានទំនុក ចិត្ត យកឈ្នះលើការផ្ទុយដែលតែងតែកើតមានជានិច្ច គឺពឹងផ្អែកទៅលើសមត្ថភាពរបស់គាត់ ដោយការបន្តរបែរទៅរកព្រះអម្ចាស់។

បើអ្នកមានអារម្មណ៍ថាអ្នកត្រូវបានគេធ្វើខុសមកលើខ្លួន ដោយមនុស្សណាម្នាក់ដូចជា (សមាជិកគ្រួសារ មិត្តភក្តិ សមាជិកណាម្នាក់នៃសាសនាចក្រ អ្នកដឹកនាំសាសនាចក្រ និងពាណិជ្ជករណាម្នាក់) ឬដោយអ្វីមួយដូចជា (សេចក្តីស្លាប់របស់មនុស្សជាទីស្រឡាញ់ មានបញ្ហាសុខភាព វិបត្តិហិរញ្ញវត្ថុ ការរំលោភបំពាន និងការញៀនថ្នាំក្តី) ចូរប្រឈមមុខនឹងបញ្ហារទាំងនោះដោយផ្ទាល់ និងប្រើអស់ទាំងកម្លាំងដែលអ្នកមាន។ «កូនកាន់ផ្លូវឱ្យខ្ជាប់» (គ. និង ស.  122:9 ) ការចុះចាញ់មិនមែនជាជម្រើសឡើយ។ ហើយចូរកុំពន្យារពេលក្នុងការបែរទៅរកព្រះអម្ចាស់។ ចូរអនុវត្តនូវសេចក្តីជំនឿទាំងអស់ដែលអ្នកមានចំពោះទ្រង់។ ចូរទុកឱ្យទ្រង់សម្រាលបន្ទុករបស់អ្នក។ ទុកឱ្យព្រះគុណរបស់ទ្រង់ សម្រាលបន្ទុករបស់អ្នក។ យើងទាំងអស់គ្នាត្រូវបានសន្យាថា យើងនឹង៖ «កុំឱ្យគេរងទុក្ខនូវសេចក្តីទុក្ខវេទនាដោយ ប្រការណាមួយឡើយ លើកលែងតែការណ៍នោះ ត្រូវបានលេបទៅក្នុង សេចក្តីអំណរនៃព្រះគ្រីស្ទប៉ុណ្ណោះ» (អាលម៉ា 31:38 )។ ចូរកុំអនុញ្ញាតឱ្យស្ថានភាពលោកិយនេះ ធ្វើឱ្យអ្នកអសមត្ថភាពខាងវិញ្ញាណឡើយ។

ទង្វើរដែលជាគំរូយ៉ាងល្អបំផុតរបស់ទ្រង់នោះគឺ  ដង្វាយធួនតម្រូវឱ្យព្រះយេស៊ូវ ចុះ «ក្រោមគ្រប់ទាំងអស់» (គ. និង ស.  88:6 ) ហើយទ្រង់រងទុក្ខ «ការឈឺចាប់នៃមនុស្សទាំងអស់» (នីហ្វៃទី 2 9:21 )។ ហេតុដូច្នេះហើយ យើងមាន ការយល់ដឹងអំពីដង្វាយធួនថា មានគោលបំណងយ៉ាងទូលំទូលាយ ជាងការដែលគ្រាន់តែផ្តល់ជាមធ្យោបាយ ដើម្បីយក ឈ្នះលើអំពើបាប។ នេះគឺជាជោគជ័យ ដ៏មហិមាជាងគេនៅលើផែនដី ដែលប្រទានឱ្យព្រះអង្គសង្គ្រោះនូវអំណាច ដើម្បីបំពេញសេចក្តីសន្យានេះ «ប៉ុន្តែបើសិនជាអ្នករាល់គ្នាបែរត្រឡប់មករកព្រះអម្ចាស់ ដោយស្មោះពីចិត្ត ហើយដាក់ទីទុកចិត្តរបស់អ្នកទៅលើទ្រង់ ហើយបំរើទ្រង់ឱ្យអស់ពីការព្យាយាមនៃគំនិតវិញ បើសិនជាអ្នករាល់គ្នា ធ្វើយ៉ាងនេះទ្រង់ នឹង...ដោះលែងអ្នកឱ្យ

រួចផុតពីសេវកភាព» (ម៉ូសាយ 7:33 )។

ខណៈពេលដែលយើងធ្វើពិធីរំឭកបុណ្យអ៊ីស្ទើរនាព្រឹកនេះ ចូរយើងបែរទៅរកព្រះអម្ចាស់ ដែលជា «ផ្កាយព្រឹកដ៏ភ្លឺចិញ្ចែង» (វិវរណៈ 22:16 )។ ខ្ញុំសូមថ្លែងទីបន្ទាល់ថាទ្រង់ជាពន្លឺបំភ្លឺផ្លូវ ជាសេចក្តីពិត និងជាជីវិតរបស់យើងជារៀងរហូត (យ៉ូហាន 14:6 )នៅក្នុងព្រះនាមនៃព្រះយេស៊ូវ គ្រីស្ទ អាម៉ែន។